# មេរៀនទី ១០៨: អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ

## ម៉ាថាយ ២:១-១២

| **គោលបំណង៖** មនុស្សគ្រប់គ្នាត្រូវការព្រះយេស៊ូវ។ |
|---|

| **ខគម្ពីរចងចាំ៖ ម៉ាថាយ ១០:១៣** *“ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ។”* |
|---|

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

មិនថាយើងនៅក្នុងដំណាក់កាលណានៃជីវិត យើងអាចថ្វាយបង្គំព្រះយេស៊ូវបានជានិច្ច។ សូមអានដំណើររឿងនៃការថ្វាយបង្គំរបស់ម៉ាហ្គីនៅក្នុង **ម៉ាថាយ ២:១-១២**។ សូមពិចារណាអំពីចំណុចនេះ៖ តើអ្នកគិតយ៉ាងណាចំពោះរបៀបដែលអ្នកថ្វាយបង្គំព្រះយេស៊ូវ? យើងអាចថ្វាយបង្គំនៅកន្លែងណាក៏បានគ្រប់ពេលដែលយើងចង់ថ្វាយបង្គំ។ ប៉ុន្តែយើងមានទំនួលខុសត្រូវដ៏ធំមួយ ដែលគ្មានអ្នកណាបង្ខំយើង(ឬមិន)ឲ្យថ្វាយបង្គំព្រះបានឡើយ។ យើងគួរតែគោរពប្រណិប័តន៍ព្រះយេស៊ូវដោយសេចក្តីស្រឡាញ់ និងការលះបង់របស់យើងចំពោះទ្រង់។ អរគុណព្រះយេស៊ូវសម្រាប់ព្រះគុណរបស់ព្រះអង្គ ដែលបានទទួលយកការថ្វាយបង្គំរបស់យើង បើទោះបីជាយើងមានបាបច្រើនក៏ដោយ។

| **ចំរៀង៖** ១. ហោរាពីទិសខាងកើត | ២. ចូរសរសើរព្រះយេស៊ូវ | ៣. ខ្ញុំថ្វាយបង្គំទ្រង់ |
|---|---|---|

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «កងចក្រណាចា»

**សម្ភារៈដែលត្រូវការ៖** គ្រាប់ប៉េងប៉ុង (ឬក៏គម្របដបទឹក, ផ្លែឈើដែលមានរាងមូល) ដបទឹក



១. ចែកកុមារជាក្រុម ដែលមួយក្រុមមានគ្នា ៤នាក់

២. ដាក់កៅអីមួយដែលមានកូនបាល់៤ និងដបទឹក៤ (ប្រើដបទឹកប្លាស្ទិក និងដាក់ទឹកក្នុងនោះ ដើម្បីកុំឲ្យដបដួល) សម្រាប់កុមារ ៤នាក់។

៣. ឲ្យក្រុមទី១ ប្រគៀកដៃគ្នា ហើយដើរទៅកាន់តុដែលមានកូនបាល់រួចយកកូនបាល់ម្នាក់មួយ។



៤. បន្ទាប់មកពួកគេត្រូវយកកូនបាល់នោះទៅដាក់ពីលើដបទឹក ដោយមិនឲ្យដួលឬក៏ធ្លាក់នោះទេ។

៥. ក្រុមណាដែលអាចដាក់កូនបាល់នៅលើដបបានច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក្រុមដែលឈ្នះបានធ្វើការជាមួយគ្នាដើម្បីសម្រេចនូវគោលដៅរបស់ពួកគេ។ ក៏ដូចគ្នានេះដែរ អ្នកប្រាជ្ញទាំង៣ នៅក្នុងព្រះគម្ពីរនៅថ្ងៃនេះ បានធ្វើការជាមួយគ្នាដើម្បីស្វែងរកព្រះយេស៊ូវ ពីព្រោះពួកយើងគ្រប់គ្នាត្រូវការព្រះយេស៊ូវ។

## ៤. ការណែនាំមេរៀន

មនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែដឹងនោះទេ។ ព្រះគម្ពីរប្រាប់យើងថាមនុស្សទាំងអស់បានប្រព្រឹត្តអំពើបាប ហើយខ្វះសិរីរុងរឿងរបស់ព្រះ។ ដោយសារយើងទាំងអស់គ្នាមានអំពើបាប យើងទាំងអស់គ្នាត្រូវការព្រះយេស៊ូវដើម្បីសង្គ្រោះយើង។ មនុស្សគ្រប់គ្នាត្រូវការព្រះយេស៊ូវ! ព្រះយេស៊ូវបាយាងមកសម្រាប់មនុស្សគ្រប់គ្នា។ ថ្ងៃនេះ យើងនឹងរៀនអំពីវិធីដែលព្រះបានដឹកនាំអ្នកប្រាជ្ញមួយចំនួនធ្វើដំណើរពីកន្លែងឆ្ងាយមកក្រុងបេថ្លេហិម ដើម្បីស្វាគមន៍ព្រះយេស៊ូវជាស្ដេច។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះយេស៊ូវប្រសូតនៅភូមិបេថ្លេហិម មានអ្នកប្រាជ្ញបីនាក់មកពីទិសខាងកើតមកក្រុងយេរូសាឡិម។

ពួកគេបានចូលទៅគាល់ស្ដេចហេរ៉ូឌជាស្ដេចនៃជនជាតិអ៊ីស្រាអែល ហើយសួរទ្រង់ថាតើស្ដេចដែលទើបកើតនោះនៅទីណា។ ស្ដេចហេរ៉ូឌមិនសប្បាយចិត្តពេលបានឮដូច្នេះ ពីព្រោះទ្រង់ជាស្ដេច។ ទ្រង់មិនចង់មានស្ដេចផ្សេងទៀតទេ។ ប៉ុន្តែអ្នកប្រាជ្ញសាសន៍ដទៃមកពីទីឆ្ងាយពន្យល់ថា ពួកគេបានមើលឃើញផ្កាយ ហើយពួកគេដើរតាមផ្កាយមួយនោះ ដែលជាសញ្ញានៃស្ដេចទើបនឹងប្រសូត។

ដូច្នេះស្ដេចហេរ៉ូឌបានហៅពួកហោរ៉ារបស់ទ្រង់ ហើយសួរពួកគេថាតើព្រះមេស្ស៊ីនឹងប្រសូតនៅទីណា។ ពួកគេបានឆ្លើយថា "នៅបេថ្លេហិម"។ ដូច្នេះ ស្ដេចហេរ៉ូឌបានប្រាប់ពួកអ្នកប្រាជ្ញឱ្យទៅភូមិបេថ្លេហិមដើម្បីស្វែងរកស្ដេចនោះ ហើយប្រាប់ឱ្យគាត់ដឹងផងដើម្បីគាត់បានទៅថ្វាយបង្គំស្ដេចថ្មីដែរ។ ប៉ុន្តែស្ដេចហេរ៉ូឌគឺចង់សម្លាប់ស្ដេចថ្មីដែលកើតក្នុងស្រុកអ៊ីស្រាអែលនោះ។

ពួកគេបានបន្តដើរតាមផ្កាយ ហើយអាចរកឃើញទារកយេស៊ូវដែលបាននៅជាមួយនឹងម្ដាយរបស់ទ្រង់។ ពួកគេរីករាយជាខ្លាំងដែលបានជួបព្រះមេស្ស៊ី ហើយបានថ្វាយបង្គំទ្រង់។ ទោះបីជាពួកគេជាសាសន៍ដទៃក៏ដោយ ពួក-គេបានដឹងថាពួកគេត្រូវការព្រះអង្គសង្គ្រោះ ហើយពួកគេរីករាយដែលបានរកឃើញទ្រង់នៅបេថ្លេហិម។ នេះជារឿងសំខាន់ណាស់ព្រោះវាបង្ហាញយើងថា ព្រះយេស៊ូវមិនគ្រាន់តែមកសម្រាប់អ៊ីស្រាអែលប៉ុណ្ណោះទេ។ ព្រះ-យេស៊ូវបានយាងមកសម្រាប់មនុស្សគ្រប់គ្នាដែលរួមមានមនុស្សមកពីអាមេរិច អឺរ៉ុប អាហ្វ្រិក ចិន អូស្ត្រាលី និងសូម្បីតែប្រទេសកម្ពុជា។ល។

យើងទាំងអស់គ្នាត្រូវការក្ដីស្រឡាញ់។ យើងទាំងអស់គ្នាត្រូវការការអត់ទោស។ យើងទាំងអស់គ្នាត្រូវការព្រះអង្គសង្គ្រោះ។ យើងទាំងអស់គ្នាត្រូវការព្រះយេស៊ូវ។ មនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ។ ហើយពេលដែលយើងទុកចិត្តលើព្រះយេស៊ូវ ហើយប្រាប់ទ្រង់ថាយើងត្រូវការទ្រង់ នោះព្រះអង្គនឹងសង្គ្រោះយើង។ យើងក៏ត្រូវតែចែករំលែកដំណឹងល្អនេះជាមួយមិត្តភ័ក្តិ និងក្រុមគ្រួសាររបស់យើងដែរ ដើម្បីឲ្យអ្នករាល់គ្នាដែលយើងស្គាល់បានស្គាល់ព្រះយេស៊ូវដែរ។ ចូរចាំថាមនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ ហើយព្រះយេស៊ូវបានយាងមកសម្រាប់អ្នករាល់គ្នា!

## ៦. សំនួរពិភាក្សា

១. តើនរណាធ្វើដំណើរមកក្រុងយេរូសាឡិមដើម្បីស្វែងរកព្រះយេស៊ូវ? *អ្នកប្រាជ្ញទាំងបីមកពីទិសខាងកើត*
២. តើនៅទីក្រុងណាដែលពួកគេបានរកឃើញព្រះយេស៊ូវដូចបានទាយក្នុងគម្ពីរ? *បេថ្លេហិម*
៣.ហេតុអ្វីរឿងនេះសំខាន់?*ព្រោះវាបង្ហាញថាព្រះយេស៊ូវមិនគ្រាន់តែប្រសូត្រមកសម្រាប់អ៊ីស្រាអែលប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់មនុស្សគ្រប់គ្នាក្នុងពិភពលោកនេះ*
៤. តើអ្នកអាចចែកចាយដំណឹងល្អនេះដល់អ្នកឯទៀតយ៉ាងដូចម្តេច? *ទុកឱ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ចាប់ផ្កាយ»

**សម្ភារៈដែលត្រូវការ៖** កែវជ័រ កូនបាល់(ឬក៏គម្របដប ឬស្ករគ្រាប់)



១. ចែកកុមារជា ២ ឬ៣ ក្រុមហើយឲ្យពួកគេឈរជាជួរ
២. ក្រុមទាំង២ ត្រូវឈរជាជួរចម្ងាយ ២ម៉ែត្រពីគ្នា។
៣. ឲ្យកូនបាល់ ៥ ទៅក្រុមនីមួយៗ។
៤. កុមារទីមួយ នឹងដាក់កូនបាល់ទៅក្នុងកែវជ័ររួចបោះវាឲ្យទៅកុមារបន្ទាប់។ កុមារបន្ទាប់ត្រូវចាប់បាល់នោះ ហើយបោះទៅឲ្យកុមារបន្តបន្ទាប់រហូតដល់កុមារចុងក្រោយ។



៥. ក្រុមណាដែលអាចបោះបាល់ទាំងអស់ទៅដល់កុមារចុងក្រោយបានមុនគេក្រុមនោះនឹងឈ្នះល្បែងនេះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កូនបាល់ប្រៀបបានដូចទៅនឹងផ្កាយអីចឹង។ បើទោះបីជាយើងពិបាកក្នុងតាមចាប់ផ្កាយក៏ដោយ យើងមិនគួរបោះបង់ការតាមស្វែងរកព្រះយេស៊ូវដូច្នេះដែរ ពីព្រោះយើងគ្រប់គ្នាត្រូវការព្រះយេស៊ូវ។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ១០:១៣

## ៩. ហត្ថកម្ម ផាត់ពណ៌រូបភាព «អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ» និងសរសេរព្រះគម្ពីរចងចាំ

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________